សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
ខុទ្ទកាល័យនាយករដ្ឋមន្ត្រីនៃគណៈរដ្ឋមន្ត្រី
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤

សូមគោរពជូន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ពួកយើង ដែលជាអ្នកបញ្ញាទិញ និង សហជីពសកល ដែលបានចុះហត្ថលេខាខាងក្រោម សូមជំរាបជូនសម្តេចតេជោ តាមរយៈលិខិតនេះ នូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការស្លាប់ និងរងរបួសរបស់កម្មករ និងអ្នកនៅជិតកន្លែងកើតហេតុ ដែលបង្កឡើងដោយកងកម្លាំងសន្តិសុខ កាលពីថ្ងៃទី២និងទី៣ខែមករាឆ្នាំ២០១៤កន្លងមកនេះ។

ការប្រើប្រាស់កម្លាំងដ៏លើសលប់ប្រឆាំងនឹងការតវ៉ារបស់កម្មករ នឹងមិនបណ្តាលឲ្យមានភាពសុខសាន្តនៃឧស្សាហកម្ម ជាយូរអង្វែងនោះទេ និងធ្វើឲ្យអន្តរាយដល់ប្រទេសកម្ពុជា ដែលជាទីតាំងប្រកបដោយស្ថេរភាពក្នុងការទិញសម្រាប់ម៉ាក អន្តរជាតិ។ ពួកយើងគាំទ្រយ៉ាងមុតមាំចំពោះសំណើររបស់អង្គការសហប្រជាជាតិ ដែលស្នើសុំឲ្យរាជរដ្ឋាភិបាលកម្ពុជា បើកការស៊ើបអង្កេតមួយជាបន្ទាន់ដោយហ្មត់ចត់ ចំពោះព្រឹត្តិការណ៍កាលពីថ្ងៃទី ២ និងទី៣ខែមករាឆ្នាំ ២០១៤។ការ ស៊ើបអង្កេតនេះគួរតែធានាឱ្យបាននូវការទទួលខុសត្រូវយ៉ាងពេញលេញ ចំពោះសមាជិកណាមួយនៃកងកម្លាំងសន្តិសុខ ដែលបានរកឃើញថាបានប្រើកម្លាំងមិនសមាមាត្រនិងហួសហេតុទៅលើបាតុករ ដើម្បីចាត់វិធានការណ៍ទប់ស្កាត់ការ កើតឡើងម្តងទៀតនៃអំពើបែបនោះ។

យើងជម្រុញឲ្យរដ្ឋាភិបាលចូលរួមជាមួយនិយោជក និងសហជីពជាបន្ទាន់ ដើម្បីចរចារកដំណោះស្រាយមួយចំពោះវិបត្តិ នេះ ដើម្បីបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការពិភាក្សាប្រកបដោយភាពជឿទុកចិត្ត និង ទៀងទាត់ រវាងកម្មករ និយោជក និង រដ្ឋាភិបាល។

មធ្យោបាយប្រកបដោយការស្ថាបនាមួយដើម្បីឆ្ពោះទៅមុខសម្រាប់ឧស្សាហកម្មនេះ គឺត្រូវតែដោះស្រាយបញ្ហាដែលជា មូលហេតុនៃជម្លោះ នាពេលបច្ចុប្បន្ន និងកន្លងមកដូចខាងក្រោម៖

**១. សិទ្ធិរបស់ជនជាប់ឃុំ.** រដ្ឋាភិបាលត្រូវគោរពសិទ្ធិរបស់មេដឹកនាំសហជីព និងកម្មករទាំង២៣នាក់ដែលបានជាប់ឃុំ ដូចពតិមានលំអិតរបស់ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។ការបរាជ័យក្នុងការធ្វើ សកម្មភាពនេះ បង្កឲ្យមានការបង្អាក់យ៉ាងធ្ងន់ធ្ងរជាមួយសិទ្ធិបុគ្គលទូទៅ និង ជាពិសេសសិទ្ធិសហជីព។

**២. គោរពសិទ្ធិសេរីភាពក្នុងការជួបជុំ.** សកម្មភាពផ្លូវច្បាប់ប្រឆាំងនឹងការរៀបចំរបស់សកម្មភាពសហជីពដែលស្របច្បាប់ រំលោភអនុសញ្ញានៃអង្គការអន្តរជាតិខាងការងារលេខ ៨៧ ដែលប្រទេសកម្ពុជាបានធ្វើសច្ចាប័ន ដោយចែងពីការការពារសិទ្ធិក្នុងការរៀបចំ។ អនុសញ្ញាបានចែងថា «គ្មានជនណាម្នាក់ ត្រូវបានដកហូតសេរីភាពរបស់ពួកគេឬត្រូវបានទទួលរងការដាក់ទណ្ឌកម្មព្រហ្មទណ្ឌសម្រាប់ការពិតនៃការរៀបចំឬចូលរួមក្នុងការធ្វើកូដកម្មដោយសន្តិវិធីណាមួយនោះទេ។» ច្បាប់អន្តរជាតិកំណត់លក្ខខណ្ឌយ៉ាងតឹងរឹងក្នុងការគោរពសិទ្ធិសហជីព ហើយ រដ្ឋាភិបាលត្រូវតែអនុលោមតាម។ អំពើហឹង្សានិងការបំផ្លាញទ្រព្យសម្បត្តិមិនមែនជាអំពើស្របច្បាប់របស់សកម្មភាពឧស្សាហកម្ម ហើយ វិធានការណ៍នៃការដាក់ទោសទណ្ឌគួរតែត្រូវបានយកមកប្រើប្រឆាំងនឹងបុគ្គលណាដែលប្រព្រឹត្តអំពើទាំងនោះ។ទោះជាយ៉ាងណាសកម្មភាពផ្លូវច្បាប់ប្រឆាំងនឹងសហជីពដែលចូលរួមនៅក្នុងការធ្វើកូដកម្មទាមទារប្រាក់ឈ្នួល រំលោភលើមូលដ្ឋាននៃសិទ្ធិការងារស្នូលនេះ ហើយវារារាំងការបង្កើតឡើងវិញនៃការពិភាក្សាក្នុងសង្គមនៅក្នុងឧស្សាហកម្មកាត់ដេរ។

**៣. ច្បាប់សហជីព.** សេចក្តីណែនាំនៃក្របខ័ណ្ឌច្បាប់ដែលស្រប នឹងអនុសញ្ញាអង្គការអន្តរជាតិខាងការងារលេខ ៨៧ និង ៩៨ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ទំនាក់ទំនងវិជ្ជាជីវៈប្រកបដោយប្រសិទ្ធិភាពគួរតែត្រូវធ្វើជាយូរណាស់មកហើយ។ យើងជម្រុញរដ្ឋាភិបាលក្នុងការចាប់ផ្តើមឡើងវិញនូវដំណើរការដែលបញ្ជាក់ពីការទទួលខុសត្រូវផ្នែកច្បាប់ទាំងនិយោជក និងកម្មករនិយោជិតដើម្បីរួមចំណែកដល់ការទំនាក់ទំនងវិជ្ជាជីវៈល្អ។

**៤. ដំណើរការកំណត់ប្រាក់ឈ្នួលថ្មី.** រដ្ឋាភិបាលចាំបាច់សរសើរចំពោះការប្តេជ្ញាចិត្តពីមុនរបស់ភាគីពាក់ព័ន្ធ ក្នុងការធ្វើឲ្យមានដំណើរការប្រកបដោយវិធីសាស្ត្រពិសេសមួយ សម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមា។ ដំណើរការថ្មីនេះគួរតែស្វែងរកកិច្ចព្រមព្រៀងជាប្រញាប់មួយចំពោះប្រាក់ឈ្នួលអប្បបរមាថ្មី និងរួមបញ្ចូលការពិនិត្យឡើងវិញជាទៀងទាត់នូវយន្តការដើម្បីពង្រឹងបន្ថែមស្ថេរភាពនៃទំនាក់ទំនងវិជ្ជាជីវៈ។ រដ្ឋាភិបាលគួរតែទទួលយកជំនួយបច្ចេកទេសពីអង្គការអន្តរជាតិខាងការងារ ដើម្បីបង្កើតយន្តការកំណត់ប្រាក់ឈ្នួលមួយដែលមានប្រសិទ្ធិភាព និង ដើម្បីបង្កើតព្រមទាំងអនុវត្តច្បាប់សហជីពមួយ។

ឧស្សាហកម្មកាត់ដេរសកលកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ហើយ ភាពសុខសាន្តនៃឧស្សាហកម្មនេះ គឺត្រូវបានទាមទារដើម្បីកសាងទំនុកចិត្តរបស់យើង ដែលជាអ្នកបញ្ជាទិញនិង សហជីពអន្តរជាតិ នៅក្នុងវិស័យឧស្សាហកម្មកាត់ដេរនៅកម្ពុជា។

យើងស្នើសុំដោយក្តីគោរព ដើម្បីឲ្យអ្នកតំណាងជាន់ខ្ពស់ដែលបានចុះហត្ថលេខាក្នុងលិខិតនេះ ចូលជួបសម្តេចតេជោនៅក្នុងសប្តាហ៍ទីមួយនៃខែកុម្ភៈ ពីថ្ងៃទី ៣ ដល់ទី៧ ខែកុម្ភៈឆ្នាំ 2014 ដើម្បីពិភាក្សាពីវិធីដែលយើងអាចជួយសម្តេចតេជោក្នុងការសម្រេចបាននូវគោលដៅដែលបានរៀបរាប់ខាងលើនេះ។

សូមសម្តេចតេជោទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

Frank Henke
Global Director, Social and Environmental Affairs
Adidas Group

Helga Ying
VP, External Engagement & Social Responsibility
American Eagle Outfitters, Inc.

Jeff Bee
Merchandise Director
Bonmarche

Philip Chamberlain
Head of Sustainable Business Development
C&A Europe

Adam Creasey
Trade Director, Global Sourcing
Debenhams

Charles Dickinson
Senior Vice President
Head of Global Quality Management and Sustainability
Esprit Holdings

Jane Randel
Senior Vice President
Corporate Communications and Corporate Social Responsibility
Fifth and Pacific Companies, Inc.

Bobbi Silten
Senior Vice President, Global Responsibility
Gap Inc.

Helena Helmersson
Head of Sustainability, H&M

Karl Gunnar Fagerlin
General Manager Global Production, H&M

Felix Poza
Global CSR Director
Inditex Sa.

Jyrki Raina
General Secretary
IndustriALL Global Union

Sharan Burrow
General Secretary
International Trade Union Confederation

David Love
Chief Supply Chain Officer
Levi Strauss & Co.

Tracy Nilsson
Director, Global Sustainability
Lululemon Athletica

Juerg von Niederhaeusern
Head of Sustainability / Social Compliance
Migros

Angela Spindler
Chief Executive
N Brown Group plc

Dr. Monica Gorman
Head of Corporate Compliance
New Balance Athletic Shoe, Inc.

Roger Wightman
Managing Director
New Look

Nick Athanasakos
Vice President, Global Sourcing & Manufacturing

Hannah Jones
Vice President, Sustainable Business & Innovation
Nike

Stefanie Reichenbach
Corporate Social Responsibility
Orsay

Paul Lister
Company Secretary
Associated British Foods

Dr. Reiner Hengstmann
Global Director
PUMA.Safe

Roopa Nair
VP, Human Rights
PVH Corp.

Dr. Sven Axel Groos
Board Member (Non Food)
Tchibo

Christophe Roussel
International Sourcing Director
TESCO

Ira M. Dansky
Executive Vice President, General Counsel and Secretary
The Jones Group Inc.

Michael J. Widman
Vice President, International Labor Standards
The Walt Disney Company

Michael Levine
Senior Counsel and Senior Director, Corporate Social Responsibility
Under Armour, Inc.

Phillip Jennings
General Secretary
UNI Global Union

Jan Saumweber
Vice President Ethical Sourcing

Ignacio Lopez
SVP Global Sourcing Operations
Walmart

ចម្លងជូន ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ